PTI0086

# សម្ភាសន៍ជាមួយឈ្មោះ សុខ រេត ភេទស្រី អាយុ៥៨ឆ្នាំ

## មុខងារជំនាន់ខ្មែរក្រហម “កម្មកររោងចក្រ”

ស្រុកកំណើតនៅភូមិត្រពាំងម្ទេស ឃុំកំពង់ត្រឡាច ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង

រស់នៅភូមិចំការជ្រៃខាងត្បូង ឃុំអន្លង់រាប ស្រុកវាលវែង ខេត្តពោធិ៍សាត់

ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១១

សម្ភាសន៍ដោយៈ សុខ វណ្ណៈ

០០:៥០:២០

២២ ទំព័រ

វណ្ណៈ : ថ្ងៃនេះទី២៣ ខែឧសភា ឆ្នាំ២០១១ មិនមុននឹងសម្ភាសខ្ញុំសុំប្រាប់ថាខ្ញុំមកពីអង្គការមជ្ឈមណ្ឌលឯកសារកម្ពុជាមីងណាស!

រេត : ចាស!

វណ្ណៈ : ហើយខ្ញុំឈ្មោះ សុខ វណ្ណៈ ខ្ញុំមកនេះគឺដើម្បីចង់ដឹងរឿងរ៉ាវនៅក្នុងភូមិហ្នឹងព្រោះកាលមុនវាជាព្រៃហើយឥឡូវនេះវាលក្លាយទៅជាភូមិករ ហើយមួយទៀតមីងធ្លាប់ឆ្លងកាត់ជាច្រើនរបបកន្លងមកមីងណាសដើម្បីយកសាច់រឿងហ្នឹងទៅចងក្រងជាសៀវភៅទុកជាប្រវត្តិសាស្ត្រដើម្បីទុកឲ្យក្មេងជំនាន់ក្រោយបានដឹងបានឮមីងណាស!

រេត : ចាស!

វណ្ណៈ : ចឹងបទសម្ភាសដែលខ្ញុំធ្វើជាមួយមីងហ្នឹងអាចឲ្យខ្ញុំយកទៅប្រើប្រាស់ចងក្រងជាសៀវភៅជាអត្ថបទឲ្យក្មេងបានដឹង បានឮបានទេមីង?

រេត : ចាស!មានទៅអី អានេះខ្ញុំយល់តាមខ្ញុំដឹ ខ្ញុំអាចប្រាប់បាន ។

វណ្ណៈ : បាទ!ចឹងមីងជាដំបូងខ្ញុំចង់ដឹងឈ្មោះមីង មីងឈ្មោះអីដែរ?

រេត : ខ្ញុំឈ្មោះ សុខ រ៉េត ។

វណ្ណៈ : សព្វថ្ងៃមីងអាយុប៉ុន្មានហើយ?

រេត : ខ្ញុំអាយុ៥៨ហើយ ។

វណ្ណៈ : ប្ដីមីងឈ្មោះអីដែរ?

រេត : ប្ដីខ្ញុំឈ្មោះឯក សុផល ។

វណ្ណៈ ៖ ឯក សុផល ។ សព្វថ្ងៃគាត់ធ្វើអីដែរ?

វេត ៖ សព្វថ្ងៃគាត់ក្រុមប្រឹក្សាស្រុក ថ្ងៃនេះគាត់ឈឺដើងអត់បានទៅធ្វើការទេ ។

វណ្ណៈ ៖ គាត់អាយុប៉ុន្មានហើយ?

វេត ៖ គាត់ហុកហើយតែមិនដឹងហុកប៉ុន្មាន!

វណ្ណៈ ៖ មីងមានកូនប៉ុន្មានមីង?

វេត ៖ កូនប្រាំនាក់ ។

វណ្ណៈ ៖ ស្រីប៉ុន្មានទៅ?

វេត ៖ ស្រីបី ប្រុសពីរ ។

វណ្ណៈ ៖ ឪពុកមីងឈ្មោះអីដែរមីង?

វេត ៖ ឈ្មោះ សុខ ស៊ិន ។

វណ្ណៈ ៖ សុខ ស៊ិន!

វេត ៖ ចា៎ គាត់ស្លាប់អស់ហើយ ។

វណ្ណៈ ៖ ម្ដាយ?

វេត ៖ អ៊ុម រ៉ាយ ។

វណ្ណៈ ៖ គាត់ទាំងពីរស្លាប់ទាំងអស់គ្នា?

វេត ៖ ចា៎!ស្លាប់អស់ហើយ ។

វណ្ណៈ ៖ គាត់ស្លាប់ជំនាន់ណា?

វេត ៖ ស្លាប់ជំនាន់៧៩ខ្លះ ហើយជំនាន់យើងឥឡូវខ្លះ ព្រោះគាត់ឈឺណាស ។

វណ្ណៈ ៖ បាទ!ក្រោយ៧៩?

វេត ៖ ចា៎!គាត់ឈឺជំងឺចាស់ ។

វណ្ណៈ ៖ គាត់ស្លាប់មីងបានទៅធ្វើបុណ្យទានឲ្យគាត់ដែរអត់?

វេត ៖ បានតែគាត់ស្លាប់ជ្រុលបាត់ហើយ តែខ្ញុំទៅធ្វើបុណ្យនៅក្រោយ ។

វណ្ណៈ ៖ ក្រោយវិញ ព្រោះកាលនោះយើងនៅជាប់ដៃនៅឡើយ!

វេត ៖ ចា៎!សភាពយើងពទ្រុសពទ្រុះគ្នាហ្នឹង!

វណ្ណៈ ៖ ស្រុកកំណើតមីងនៅភូមិអីដែរមីង?

វេត ៖ ខ្ញុំនៅឃុំ...

វណ្ណៈ ៖ ចុះភូមិ?

វេត ៖ ភូមិត្រពាំងម្ទេស...ឥឡូវហ្នឹងហ្អី?

វណ្ណៈ ៖ អត់ទេភូមិកំណើតកាលដែលមីងកើត ។

វេត ៖ ចា៎! ខេត្តកំពង់ឆ្នាំង ស្រុកកំពង់ត្រឡាច ឃុំស្វាយជុក ភូមិត្រពាំងម្ទេស ។

វណ្ណៈ ៖ ភូមិត្រពាំងម្ទេស...ឃុំកំពង់ត្រឡាច កំពង់ត្រឡាចលើហ្អី?

វេត ៖ លើ ។

វណ្ណៈ ៖ ស្រុកកំពង់ត្រឡាចដែរ?

វេត ៖ សាមគ្គីមានជ័យ ចង់ភ្លេចអស់ហើយមកយូរពេក ។

វណ្ណៈ ៖ ខេត្តកំពង់ឆ្នាំង?

វេត ៖ ចា៎!

វណ្ណៈ ៖ ឥឡូវមីងរស់នៅភូមិអី?

វេត ៖ ខ្ញុំរស់នៅភូមិចំការជ្រៃខាងត្បូង ។

វណ្ណៈ ៖ ឃុំ?

វេត ៖ ឃុំអន្លង់រាប ។

វណ្ណៈ ៖ ស្រុក?

វេត ៖ វាលវែង ។

វណ្ណៈ ៖ ខេត្ត?

វេត ៖ ខេត្តពោធិ៍សាត់ ។

វណ្ណៈ ៖ បងប្អូនមីងបង្កើតប៉ុន្មាននាក់?

វេត ៖ បងប្អូនបង្កើត៦នាក់ ។

វណ្ណៈ ៖ សព្វថ្ងៃនៅសល់ប៉ុន្មាន?

វេត ៖ សព្វថ្ងៃនៅសល់ស្រី៤ ប្រុស...ចាំខ្ញុំរាប់សិនភ្លេចអស់ហើយ....ស្រី៥ ប្រុស១ ៦នាក់ ។

វណ្ណៈ ៖ នៅរស់ទាំងអស់គ្នាហ្អី?

វេត ៖ ចា៎!

វណ្ណៈ ៖ កាលពីតូចមីងរៀនបានដល់ណា?

វេត ៖ រៀនដល់ថ្នាក់ទី៨ ។

វណ្ណៈ ៖ ថ្នាក់ទី៨ចាស់ហ្ន៎?

វេត ៖ ចា៎!

វណ្ណៈ ៖ ចឹងមីងចេះមើលចេះអានដែរ ថ្នាក់ទី៨ពីដើមគួរសមដែរ?

វេត ៖ ចេះមើលតើក្មួយ តែឥឡូវវាភ្លេចខ្លះហើយយើងមិនសូវដែររវល់ ។

វណ្ណៈ ៖ ចុះយ៉ាងម៉េចបានមីងឈប់រៀន?

រេត ៖ កាលដែលខ្ញុំឈប់រៀនហ្នឹងស្រុកគេកើតសង្រ្គាមនោះ ។

វណ្ណៈ ៖ កើតសង្រ្គាមហ្អី? ឆ្នាំ៧០ រដ្ឋប្រហារហ្នឹងហ្អី?

រេត ៖ ចា៎! រដ្ឋប្រហារហ្នឹងបានគ្រូៗរត់អស់ ។

វណ្ណៈ ៖ ឈប់រៀនមីងធ្វើអីវិញ?

រេត ៖ ឈប់រៀនខ្ញុំនៅភូមិនៅជាមួយឪពុកម្ដាយហ្នឹងណាស ។

វណ្ណៈ ៖ ជួយឪពុកម្ដាយ?

រេត ៖ ចា៎!

វណ្ណៈ ៖ ចុះក្រោយមកទៀត?

រេត ៖ ក្រោយមកទៀតចេញពីឪពុកម្ដាយឆ្នាំ៧៥ ហ្នឹងខ្ញុំនៅភ្នំពេញ ។

វណ្ណៈ ៖ ចេញមកនៅភ្នំពេញម៉ងហ្អី?

រេត ៖ ចា៎!

វណ្ណៈ ៖ ព្រោះថា៧៥ គេរំដោះបានហើយហ្ន៎?

រេត ៖ ចា៎! ហ្នឹងហើយ ។

វណ្ណៈ ៖ កាលនោះអ្នកណាចាត់តាំងមីងមកភ្នំពេញ?

រេត ៖ គូរដណ្ដឹងគ្រួសារយើងប្ដីប្រពន្ធហ្នឹងណាស គេដូចថាខ្ញុំហ្នឹងគូដណ្ដឹងគេហើយ គេនៅធ្វើការនៅភ្នំពេញហ្នឹងក៏គេយកទៅភ្នំពេញនៅភ្នំពេញបណ្ដោយ ។

វណ្ណៈ ៖ ហ៊ុស! ៧៥ យើងម៉េចការបានមានតែរៀបជាគូរៗ ។

រេត ៖ ចាស ហ្នឹងហើយរៀបតែគ្រាន់តែខ្ញុំនិយាយថាការ ។

វណ្ណៈ ៖ ចុះមីងហើយពូការតាំងពី៧៥មកម៉េះ?

រេត ៖ ខ្ញុំអីចេះក្មួយ! ខ្ញុំគ្រួសារពីរហើយ គ្រួសារដែលរៀបនៅភ្នំពេញហ្នឹងស្លាប់ហើយ ។

វណ្ណៈ ៖ ឆ្នាំ៧៥ ហ្នឹង?

រេត ៖ ស្លាប់នៅ៧៩ ។

វណ្ណៈ ៖ បាទ! ប៉ុន្ដែពេលនៅឆ្នាំ៧៥ ហ្នឹង...

រេត ៖ ខ្ញុំនៅភ្នំពេញរហូតដល់៧៩ ហ្នឹង ។

វណ្ណៈ ៖ អីចេះដូចថាពេល៧៥ ហ្នឹងធ្វើម៉េចបានមីងទាក់ទងពូមកនៅភ្នំពេញបាន?

រេត ៖ ខ្ញុំមិនមែនទាក់ទងទេក្មួយចង់និយាយថា...

វណ្ណៈ ៖ អង្គការបញ្ជូនឲ្យទៅទេហ្អី?

រេត ៖ អត់មានអង្គការអីទេ ឪពុកម្ដាយខាងប្រុសហ្នឹងហើយឪពុកម្ដាយខាងខ្ញុំ ។ ឪពុកម្ដាយខាងប្រុសហ្នឹងគេមកនិយាយជាមួយម៉ែខ្ញុំចាស់ៗហើយចាស់ៗហ្នឹង គេមកនិយាយក៏ម៉ែខ្ញុំឲ្យ ។ ដល់ឲ្យចឹងទៅ ម្ដីខ្ញុំមុនហ្នឹងគាត់ធ្វើទាហាន...

វណ្ណៈ ៖ យោធាខ្មែរក្រហម?

រេត ៖ ចាស ដល់ចឹងទៅគេនៅចាំនៅភ្នំពេញហ្នឹងណាស ដល់ទៅគេយកខ្ញុំទៅរៀបនៅនោះទៅ ។

វណ្ណៈ ៖ ចឹងអ្នកស្រុកអ្នកភូមិជាមួយគ្នាហ្អី?

រេត ៖ អ្នកស្រុកអ្នកភូមិឆ្ងាយពីគ្នា គាត់នៅឃុំទួលលាបឯណោះហើយគេយកទៅរៀបនៅភ្នំពេញ នៅភ្នំពេញរហូត ។

វណ្ណៈ ៖ កាលនោះមិនមែនអង្គការបញ្ជូនទៅទេហ្ន៎?

រេត ៖ អត់ទេ!

វណ្ណៈ ៖ បាទ! ពេលដែលមីងទៅរៀបហ្នឹងចូលសម័យខ្មែរក្រហមហើយហ្ន៎?

រេត ៖ ចាស!

វណ្ណៈ ៖ ចុះឪពុកម្ដាយមីងបានទៅទេ?

រេត ៖ អត់បានទៅផង ។

វណ្ណៈ ៖ ហើយខាងឪពុកម្ដាយខាងប្រុសគេនៅនោះស្រាប់?

រេត ៖ គេនៅទីនោះ ។

វណ្ណៈ ៖ ទៅដល់អង្គការចាត់តាំងរៀបឲ្យទៅ?

រេត ៖ ចា៎ គ្រាន់តែថាការហ្នឹងគេមិនចាប់បង្ខំទេព្រោះយើងគូដណ្ដឹង គូដណ្ដឹងចាស់ៗដឹង ។

វណ្ណៈ ៖ ចុះដល់មីងការហើយ?

រេត ៖ ខ្ញុំនៅធ្វើការរោងចក្រ ។

វណ្ណៈ ៖ រោងចក្រអីគេ?

រេត ៖ រោងចក្រចក្រអង្រែថ្មពិលណាសនៅតាខ្មៅ ។

វណ្ណៈ ៖ ថ្មពិលតាខ្មៅហ្អី?

រេត ៖ ចា៎!

វណ្ណៈ ៖ ចុះអ្នកណាប្រធាន?

រេត ៖ ប្រធានរោងចក្រហ្នឹងហ្អី?

វណ្ណៈ ៖ បាទ!

រេត ៖ បងសៀ! ឈ្មោះសៀ មិនដឹងឈ្មោះអី សៀ ទេដឹតាគាត់ខ្ញុំមិនដឹងដែរ ។

វណ្ណៈ ៖ ឈ្មោះសៀ ចុះក្រោយមកគេមានចាប់ខ្លួនគាត់ទេ?

វេត ៖ អត់ផង ។

វណ្ណៈ ៖ គាត់កាន់រហូតដល់៧៩ហ្អី?

វេត ៖ ចា៎!

វណ្ណៈ ៖ ចុះមីងថាធ្វើការនៅរោងចក្រពិលហ្នឹងគេធ្វើម៉េចខ្លះ គេលាយអីខ្លះ?

វេត ៖ គេយកវត្ថុធាតុដើមអាកាទុសអាអីហ្នឹងគេយកពីប្រទេសចិនមក ជាតិគីមីជាតិអីហ្នឹង ។

វណ្ណៈ ៖ ចុះវត្ថុធាតុដើមហ្នឹងមានអីគេខ្លះ?

វេត ៖ ខ្ញុំអត់នៅអាខាងលាយថ្នាំហ្នឹងផង វាមានផ្នែកវាណាស់ក្មួយ អាខាងលាយហ្នឹងផ្សេងទៅ អាផ្នែកធ្វើបណ្ដូលហ្នឹងផ្សេងទៅ អាផ្នែកកាត់ម៉ាកហ្នឹងផ្សេងទៅ ដល់ហើយទៅមានអាផ្នែកគេរុំស័កជាថ្មពិលទៅហើយបណ្ដោយ ។ ហើយខ្ញុំនៅខាងកាត់ម៉ាក កាត់កំប៉ុងហ្នឹងទៅ ។

វណ្ណៈ ៖ ចុះគេមានដាក់អក្សរទេម៉ាកហ្នឹង?

វេត ៖ ម៉ាកគេដាក់អក្សរថា តុ ម៉ឹកអីចឹងឯងគេដាក់រូបរោងចក្រហ្នឹងតែម៉ង ។

វណ្ណៈ ៖ ហ្អស!រោងចក្រហ្នឹងមានកម្មករប្រហែលប៉ុន្មាននាក់ដែរ?

វេត ៖ កម្មករប្រហែល៦០០នាក់ ។

វណ្ណៈ ៖ ៦០០នាក់ទាំងស្រីទាំងប្រុសហ្អី?

វេត ៖ ទាំងស្រីទាំងប្រុសគ្រប់ផ្នែកទាំងអស់ ទាំងសេដ្ឋកិច្ចទាំងអី ។

វណ្ណៈ ៖ ចុះកាលដែលគ្រួសារមីងមុនហ្នឹងឈ្មោះអីដែរ?

វេត ៖ ឈ្មោះ ណាំ វុទ្ធី ។

វណ្ណៈ ៖ ណាំហ្អី?

វេត ៖ ណាំ វុទ្ធី ។

វណ្ណៈ ៖ គាត់ប្រហែលជាអាចមានឋានៈធំដែរបានអាចហៅមីងទៅរៀបនៅទីនោះបាន កាលនោះគាត់ឡើងធំដែរហ្អី ប្រធានអីដែរហ្អី?

វេត ៖ គាត់កាន់តំណែងតិចតួចដែរហ្នឹងព្រោះអី...

វណ្ណៈ ៖ ប្រធានវរៈអីដែរហ្អី?

វេត ៖ ចាស ប្រហែលចឹងហើយខ្ញុំមិនដែលសួរយកចិត្តទុកដាក់ផងខ្ញុំនៅក្មេងណាស់កាលនោះណាស បើគាត់ស្លាប់បាត់តាំងពីយូរហើយ ។

វណ្ណៈ ៖ បាទ!ចុះមីងការហើយហ្នឹងបានរស់នៅជួបជុំប្ដីប្រពន្ធដែរអត់?

វេត ៖ ចា៎!នៅ ។

វណ្ណៈ : ចុះមីងកាលជំនាន់ខ្មែរក្រហមមានកូនមានអីដែរ?

រេត : មានកូនមួយតែគ្រាន់តែថាជិតផុតហើយបានមានកូន ។

វណ្ណៈ : ហ្អស!

រេត : នៅជុំគ្នានៅផ្សារថ្មី ខ្ញុំនៅរោងចក្រ ខែគ្រាន់តែថាល្ងាចឡើងទៅផ្សារថ្មីនៅជុំគ្នា ។

វណ្ណៈ : នៅផ្សារថ្មីហ្នឹងគាត់ធ្វើអីគេ?

រេត : គាត់នៅកន្លែងឡានណាស ទទួលកន្លែងឡានណាស ឡានដែលគេហៅថាមន្ទីរខស្បៀងហាកម្មរដ្ឋ កន្លែងឡានណាស!

វណ្ណៈ : បាទ!

រេត : ដូចថាគេត្រូវការយកទៅណេះប៉ុន្មានណោះប៉ុន្មានចឹងណាស ។

វណ្ណៈ : មីងនៅរោងចក្រ ល្ងាចឡើងជួបជុំគ្នា?

រេត : ចាំ ជុំគ្នា ។

វណ្ណៈ : មីងឃើញស្ថានភាពនៅភ្នំពេញស្ងាត់ ឬអ៊ូរអរមានបរទេសអីដែរទេ?

រេត : កាលពីសម័យបីឆ្នាំហ្នឹងហ្អីក្មួយ?

វណ្ណៈ : បាទ!

រេត : កាលនោះទីក្រុងភ្នំពេញវាមានពេលស្ងាត់ វាមានពេលអ៊ូអរ ដូចថាជនជាតិបរទេសវាមានគ្រប់ដែរ វាមានជនជាតិបារាំង គុយបា ជប៉ុន ចិនមានគ្រប់ទាំងអស់ តែគេនៅកន្លែងគេណាស ។ ដូចថាល្ងាចឡើងគេជិះកង់ គេជុះឡានគេដើរលេងដឹកដៃគ្នាចុះឡើងចឹងណាសក្មួយខ្ញុំឃើញ ។

វណ្ណៈ : ឃើញចឹងរហូតដល់៧៩ឬកាន់តែតិចទៅៗ ។

រេត : មានរហូតទាល់តែយើងរត់ហ្នឹងបែកគ្នាអស់ទៅ ។

វណ្ណៈ : បាទ!ចុះមីងកាលនៅរោងចក្រថ្មពិលហ្នឹងដែលមានគណៈប្រតិភូធំៗទៅមើលទេ?

រេត : គណៈប្រតិភូមានត្រឹមតែលោក ចេង អន...

វណ្ណៈ : បាទ!តា ចេង អន ហ្អី?

រេត : ចាស ហើយតា វន វេត អីហ្នឹង តែគាត់ស្លាប់អស់ហើយ ។ ក្មួយដែលឮឈ្មោះទេតា ចេង អន?

វណ្ណៈ : ឮ!មីងដឹងថាតា វន វេត តាចេង អន គេចាប់ខ្លួនដោយសារអីទេ?

រេត : អត់ដឹង ។

វណ្ណៈ : ដឹងតែថាគេចាប់ពួកគាត់នែ?

រេត ៖ ដឹងតែថាដល់ពេលមើល....ឆ្នាំ១៩៧៧បាត់គាត់ តែមិនដឹងទៅណាយើងមិនដឹងដែរ ៧៧ ៧៨ អីហើយយូរហើយយើងមិនសូវចាប់អារម្មណ៍ ។

វណ្ណៈ ៖ ចុះពីណាទៅមើលវិញនៅពេលបាត់គាត់?

រេត ៖ អត់ទាន់ឃើញពីណាផងព្រោះខាងលើខ្ញុំអត់សូវយល់ណាក្ហយ ព្រោះយើងប្រជាជនធម្មតា យើងមិនអាចដឹងរឿងគេណាស ។

វណ្ណៈ ៖ ចឹងមីងរយៈពេលបីឆ្នាំជាងមីងដែលមកលេងស្រុកកំណើតទេ?

រេត ៖ ដែលតើ?

វណ្ណៈ ៖ សុំគេបានដែរ?

រេត ៖ ចា៎!

វណ្ណៈ ៖ ហើយចុះពេលមកដល់ស្រុកភូមិឃើញម៉េចដែរហូបចុកអី?

រេត ៖ ប្រជាជននៅភូមិខ្ញុំដែលខ្ញុំមកហ្នឹង ហើយឪពុកម្ដាយខ្ញុំហ្នឹងគាត់នៅក្នុងសហករណ៍ ។ សហកណ៍ហ្នឹងគាត់ហូបបាយរួមអីចឹងណាសក្ហួយ អត់ឃើញមានអីទៀតផង ។

វណ្ណៈ ៖ ឆ្នាំណាដែលមីងមកលេងភូមិ?

រេត ៖ ឆ្នាំ៧៨ ។

វណ្ណៈ ៖ ចឹងឆ្នាំ៧៨?

រេត ៖ ចាស ឆ្នាំ៧៦ខ្ញុំមកដែរ តែអត់ទាន់ឃើញអីទេហូបធម្មតាចឹងដល់ឆ្នាំ៧៨ខ្ញុំឃើញគេហូបបែកបាយបែកអីចឹងណាស ឃើញតែអីចឹងអត់មានឃើញអីទៀតផង ។

វណ្ណៈ ៖ ចុះមីងដឹងថាមានអ្នកស្លាប់ដោយសារអត់បាយអីមានទេ?

រេត ៖ អត់មានដឹងអាលីងអត់មានដឹងរឿងរ៉ាវព្រោះងយើងនៅភ្នំពេញយើងដឹងតែការងារយើង អត់មានដឹងអាលីង ។

វណ្ណៈ ៖ ចុះកាលមីងមកលេងស្រុកនៅកំពង់ស្ពឺហ្នឹងមានដឹងអ្នកណាគណៈស្រុកទេ?

រេត ៖ ខ្ញុំអត់ស្គាល់ទេ ។

វណ្ណៈ ៖ តែដល់ពេលមីងត្រលប់ទៅភ្នំពេញវិញមានគេតាមដានដែរអត់?

រេត ៖ អត់ទេ ។

វណ្ណៈ ៖ ចឹងអត់អីដែរហ្អី?

រេត ៖ ចាស អត់មានអីផង ខាងខ្ញុំអត់មានអីទេ ។ ពេលយើងមកលេងចឹងអ្នកស្រុក មេភូមិមេអីគេមកលេងចឹង សួរសុខទុក្ខកូនគេអីចឹងទៅណាស ឃើញកូនខ្ញុំដែរអត់អីចឹងទៅណាសធម្មតាអត់មានអីផង ។

វណ្ណៈ ៖ ចុះកាលនោះមីងដូចប្តីមីងអីអត់មានអីដែរ?

រេត ៖ អត់មានអីទេ ។

វណ្ណៈ ៖ គាត់នៅធ្វើការរហូតដល់៧៩?

រេត ៖ គាត់នៅទទួលខុសត្រូវនៅកន្លែងឡានរហូតដល់៧៩ ឆ្នាំ៨០ ៨១គាត់ស្លាប់ ។

វណ្ណៈ ៖ គាត់ស្លាប់ដោយសារអី?

រេត ៖ ឈឺនៅថៃ ។

វណ្ណៈ ៖ គាត់ឈឺអីគេ?

រេត ៖ មិនដឹងឈឺអីទេក្មួយបើអត់បានមួយយប់ផងវាក្លាម១ចឹងណាសដល់ពេលព្រឹកឡើងគាត់និយាយប្រាប់ខ្ញុំថាដូចរាងអត់ស្រួលខ្លួនមីអូនហ្អា!គាត់ហៅខ្ញុំអាវឿន១ចឹងណាស!អាវឿនដូចអត់ស្រួលខ្លួនណាស ហើយបងឯងចេះម៉េចចោះ?ដូចអត់ស្រួលខ្លួនរសេះសោះយ៉ាងម៉េចមិនដឹងទេ កោសខ្យល់ឲ្យគ្នាតិចមើល!។ ដល់កោសខ្យល់ទៅក៏គាត់ចេះតែថាអត់ស្រួលក្នុងខ្លួនម៉ោងបីហើយដាក់ស៊ីរ៉ូមតាំងពីកោសខ្យល់ហើយដល់ម៉ោង៣គាត់ស្លាប់ ។

វណ្ណៈ ៖ លើសឈាមប្តូក៏អី?

រេត ៖ មិនដឹងធាត់ឲ្យធ្នូលហើយប្តីខ្ញុំគាត់ស ខ្ពស់ ។

វណ្ណៈ ៖ បាទ!

រេត ៖ អត់មានស្គមអីទេ ។

វណ្ណៈ ៖ ចឹងខ្ញុំចង់សួរបកទៅកាលនៅភ្នំពេញហ្នឹងដូចថាមីងអត់ដែលឃើញ ប៉ុល ពត ខៀវ សំផន នួន ជាអីទៅលេងទេ?

រេត ៖ អត់ទេ អត់ដែលស្គាល់ផងខ្ញុំ ។

វណ្ណៈ ៖ នៅកន្លែងមីងហូបចុកគ្រប់គ្រាន់ទេ?

រេត ៖ ចាំ!ធម្មតាមួយថ្ងៃបីពេល ។

វណ្ណៈ ៖ អូ!បានច្រើន ។

រេត ៖ ព្រលឹមឡើងគេឲ្យហូបបបរដល់ពេលថ្ងៃត្រង់យើងចេញពីរោងចក្រមកហូបបាយ ល្ងាចហូបបាយ ។ ដល់ឆ្នាំ៧៨ ៧៩ហ្នឹងគេឲ្យហូបនំប៉័ង នំប៉័ងឲ្យហូបមាំគ្រប់ម៉ាគ្រាន់ដល់ពេលដំបូងយើងហៅបាយដែលណាសក្មួយ ដល់ពេលហូបបានប្រហែលមួយខែទៅអត់មាននឹកនាបាយទេ ។

វណ្ណៈ ៖ ស៊ាំហើយ!

រេត ៖ ចាំ!ស៊ាំចង់តែហូបនំប៉័ងទេ ។

វណ្ណៈ : ដល់ហូបនំប៉័ងគេមានសម្លរដែរ?

វេត : សម្លរមាន សម្លរគេពីរមុខបីមុខរហូតគេអត់មានឲ្យខ្វះខាតទេ នំប៉័ងពេញបឹបតែម៉ង ។

វណ្ណៈ : ចុះដល់ពេលនៅសម័យនោះវាមានដូចខ្សែៗណាស ឧបមាថាគេចាប់មេៗចឹងទៅនៅតាមភូមិភាគផ្សេងៗឧបមាថា គេចាប់ សោ ភឹមបាត់ទៅ អ្នកបូព៌ា ដូចថាកម្មករ ជាទាហានផ្សេងៗត្រូវបានគេតាមដានឬចាប់ខ្លួនបន្តបន្ទាប់ទៀត ។ នៅកន្លែងមីងមានទេ មានបាត់ខ្លួនអីខ្លះទេ?

វេត : បាត់ បាត់ខ្លះដែរ ខែគ្រាន់តែថាយើងអត់ដឹងណាស យើងអត់ដឹងថាប្រធានផ្នែកប្រធានអីហ្នឹង ។ គ្រាន់តែថា ចុមបាត់បងនាងអីទៅណា ចឹងទៅណាស ដល់នេះទៅគេថាគាត់ផ្លាស់ទៅធ្វើខាងនោះអីចឹងទៅណាសក្មួយ ហើយយើងក៏ស្ងាត់ស្ងួរទៅណាសអត់មានដេញដេលអីទៀតទេ ។ អាហ្នឹងខាងបូព៌ាណាស ។

វណ្ណៈ : ចុះកម្មករធម្មតាមានបាត់ខ្លួនខ្លះដែរ?

វេត : អត់ ។

វណ្ណៈ : បាត់តែប្រធានៗទេនែ?

វេត : ចា៎!

វណ្ណៈ : កាលនោះដូចថាហូបចុកគ្រប់គ្រាន់ទេ តែគ្រាន់តែថាគេតាមដានយើងខ្លាចមានសមាសភាពមិនល្អអីចឹងមានបាត់ខ្លួនមួយចំនួនដូចអ្នកនៅបូព៌ាអីចឹងហ្អី?

វេត : ចា៎! គេប្រឆាំងជាមួយពួកបូព៌ាគេតាមដានចឹងទៅណាស តែយើងមិនដឹងគេតាមដានរឿងអីៗចឹងទៅណាស ។

វណ្ណៈ : ចុះកាលនៅភ្នំពេញហ្នឹងមីងមានដឹងថាមានគុកទួលស្លែងទេ?

វេត : គុកទួលស្លែងខ្ញុំដឹងតាំងពីមុនមកថាមាន តែគ្រាន់តែថាដាក់អីៗចឹងខ្ញុំអត់ដឹងទេ ។

វណ្ណៈ : ដឹងតាំងពីពេលណា ដំបូង?

វេត : ដឹងតាំងពីមកនៅភ្នំពេញ ។

វណ្ណៈ : តាំងពី៧៥ហ្នឹង?

វេត : ចា៎! តែគ្រាន់តែគុកទួលស្លែងប៉ុណ្ណាៗ យើងមិនដឹង ។

វណ្ណៈ : ចឹងកាលនោះមីងអត់ស្គាល់ឌុចទេហ្អី?

វេត : អត់ ។

វណ្ណៈ : ទើបតែស្គាល់ទេ?

រេត ៖ ស្គាល់ពូតាមរ៉ាត់យូ ទូរទស្សហ្នឹងឯង ដល់តែពូថាតា ឌុច ហ្នឹង មើលអីណាមុខយ៉ាងម៉េច អញមិនដែលឃើញ...ពួសូរតែគេថាអីចឹងអត់ដែលដឹង ។

វណ្ណៈ ៖ ចុះកាលជំនាន់បីឆ្នាំហ្នឹងមីងមានឋានៈជាប្រធានអីខ្លះដែរទេ?

រេត ៖ អត់ នារីសុទ្ធសាតអត់មានទៅទទួលអីនឹងគេទេ ។

វណ្ណៈ ៖ អត់មានជាប្រធានក្រុម ប្រធានខ ប្រធានកអីទេ?

រេត ៖ អត់...គេមិនឲ្យយើងធ្វើទេយើងក្មេងៗ ។

វណ្ណៈ ៖ ចុះកាលនោះមីងឃើញគុយបា ឃើញជប៉ុនអីដែរហ្អី?

រេត ៖ ចាំ!ឃើញចិន ឃើញកូរេអីហ្នឹងឯង ។

វណ្ណៈ ៖ ម៉េចមីងដឹងថាជប៉ុន?

រេត ៖ ចុះអ្នកបកប្រែខ្មែរយើង ខ្មែរយើងគេប្រាប់ដូចយើងស្គាល់គ្នាអីចឹងណាស ។

វណ្ណៈ ៖ ចុះកាលនោះយើងស្លៀកពាក់ម៉េចដែរ ខ្មៅៗឬម៉េចដែរ?

រេត ៖ ខ្ញុំស្លៀកពាក់...ពេលនេះ...តែភាគច្រើនគឺខ្មៅ ខែខ្ញុំកម្មករចឹងវាមានខៀវ ។

វណ្ណៈ ៖ ខៀវ?

រេត ៖ ចាំ!តែដូចម្ហូកខៀវអីចឹងណាស ។ ម្ហូកខៀវចឹងទៅ អាវខៀវចឹងទៅជួនកាលអាវខ្មៅចឹងទៅណាស ធម្មតា ។ ដល់ពេលយើងចេញពីរោងចក្រចឹងស្លៀកពាក់ធម្មតាទៅ ។

វណ្ណៈ ៖ ខ្មៅហ្អី?

រេត ៖ ពាក់អាវផ្កាអាវអីចឹងទៅចុះយើងឈប់ធ្វើការហើយនោះ ។

វណ្ណៈ ៖ ចុះយើងអាចពាក់អាវផ្កាអាវអីបានដែរ គេអត់ថាអីទេ?

រេត ៖ គេអត់ថាអីផងអាហ្នឹងខ្ញុំនិយាយតែអគ្គភាពខ្ញុំទេណាស អគ្គភាពខ្ញុំគេអត់មានប្រកាន់អីទេ ។

វណ្ណៈ ៖ អគ្គភាពមីងនៅតាខ្មៅនៅម្តុំណា?

រេត ៖ នៅចក្រអង្រែហួសក្បាលថ្នល់បន្តិច ។

វណ្ណៈ ៖ ហួសនៅចក្រអង្រែហ្អី?

រេត ៖ ចាំ! រោងចក្រថ្មពិល គេហៅសុខ ម៉ឺក ពីមុនណាស តែឥឡូវមិនដឹងគេដាក់រោងចក្រអីខ្ញុំមិនដឹងដែរ ។

វណ្ណៈ ៖ សុខ ម៉ឺកហ្អី?

រេត ៖ ចាំ!សុខ ម៉ឺក

វណ្ណៈ ៖ ម៉េចបានគេដាក់ឈ្មោះអីចឹងមីងហ្ន៎?

រេត ៖ អត់ដឹង ថៅកែរោងចក្រ ពេលខ្ញុំទៅឃើញគេដាក់ឈ្មោះអីចឹង ។

វណ្ណៈ ៖ ចុះមីងថ្មពិលហ្នឹងមានដឹងគេនាំចេញគេដឹកយកទៅណា គេផលិតបានច្រើនទេ?

រេត ៖ ឮសួរគេថាយកទៅចិន ។

វណ្ណៈ ៖ ដូចថាយើងធ្វើបានច្រើនទេកាលនោះ?

រេត ៖ ច្រើនណាស់ក្មួយ ។

វណ្ណៈ ៖ ចុះក្រៅពីរោងចក្រមីងឃើញគេធ្វើអីទៀតនៅភ្នំពេញហ្នឹង?

រេត ៖ ឃើញគេធ្វើរោងចក្របារី រោងចក្រក្រណាត់ ថ្មពិលហ្នឹងហើយហ្នឹងក្រដាស ។ និយាយរួម ច្រើនដែររោងចក្រគោកកដី កាត់ដេរកាត់អីហ្នឹង ។

វណ្ណៈ ៖ បាទ!ចឹងកាលនោះអគ្គិសនី ភ្លើងអីយើងដេកម៉េចដែរ យើងដេកផ្ទះថ្ម?

រេត ៖ ធម្មតាមានកង្ហារបើកទល់ភ្លឺ ។

វណ្ណៈ ៖ ចឹងមីងអាចដើរលេងក្នុងផ្សារអីបានទេ?

រេត ៖ ចូលផ្សារវាមានតែរបស់បើក ចូលផ្សារមានលុយឯណាចាយដូចថាព្រលឹមអីចឹងខាងផ្នែកសេដ្ឋកិច្ចគេមកបើកម្ហូបនៅផ្សារថ្មី គេបើកឡានមកដាក់នៅផ្សារថ្មី ដឹកនំបុ័ង ដឹកត្រី សាច់ អីចឹងទៅយកទៅធ្វើទៅ ។

វណ្ណៈ ៖ ចុះមីងដូចថានៅខាងកម្មករខស្សរាមានប្រជុំមានអីដែរ?

រេត ៖ ប្រជុំក្រុម ឲ្យចេះស្រលាញ់គ្នាអីចឹងទៅណាស ។ គេអប់រំថាកុំឲ្យមានបញ្ហាអីចឹងណាសកុំឲ្យមានទំនាស់ឲ្យចេះសាមគ្គីគ្នាចឹងទៅណាស ។

វណ្ណៈ ៖ ចុះកាលនោះមីងមានដឹងថាសម្តេចសីហនុនៅក្នុងវាំងគេឃុំគាត់នៅក្នុងវាំងដែរទេ?

រេត ៖ សម្តេចសីហនុខ្ញុំអត់ដែលបានឃើញគាត់តែគ្រាន់តែថាកាលដែលខ្ញុំដឹងគាត់ទៅចិនបាត់ ហើយគេយកទៅចិនអស់ហើយ ។

វណ្ណៈ ៖ ឆ្នាំណាដែលគេយកទៅចិន?

រេត ៖ ភ្លេចបាត់ហើយក្មួយមិនដឹងឆ្នាំទេ ឆ្លើយទៅខ្លាចលវាខុស ។

វណ្ណៈ ៖ ចុះមីងកាលនោះមានដែលទទួលគណៈប្រតិភូ ឧបមាថាគណៈប្រតិភូបរទេសមកចឹងគេឲ្យនារីទៅទទួលទៅអីទេ?

រេត ៖ ចាសទៅទទួលនៅមហោស្រព ។

វណ្ណៈ ៖ ចឹងទៅទទួលដែរ?

រេត ៖ ចា៎!ទៅអីចឹងយើងស្លៀកពាក់ហូល ដាមួងអីទៅ អាវប៉ាក់ដៃត្រឹមហ្នឹងទៅ ។

វណ្ណៈ ៖ បាទ!ដល់ពេលទទួលហើយគេដោះយកវិញអស់?

រេត ៖ អត់ទេ គេឲ្យយើង ។

វណ្ណៈ : គេឲ្យយើងដែរ?

វេត : ចា៎!ដល់ពេលថ្ងៃណាយើងត្រូវការគេមានការទៅទទួលគណៈប្រតិភូមកពីណាខាងកូរ៉េអីចឹង យើងស្លៀកពាក់ទៅ ឡានក្រុងគេទៅដឹកយើង ។

វណ្ណៈ : ចឹងអាហ្នឹងគេឲ្យយើងស្លៀកពាក់តែសំរាប់ធ្វើការទេ អត់មានធ្វើការអីទេ?

វេត : អាហ្នឹងស្លៀកម៉េចកើតជាមួង ហូលអី ។

វណ្ណៈ : មីងដែលទទួលភ្ញៀវចិន ភ្ញៀវកូរ៉េអីដែរ?

វេត : ដែល ។

វណ្ណៈ : ចុះអត់ដែលទទួលសម្ដេចចុះមកអីទេ?

វេត : សម្ដេចអត់ អត់ដែលបានឃើញផង ។

វណ្ណៈ : តាមពិតសម្ដេចចេញចូលរហូត ហើយដល់ក្រោយមកគេឃុំខ្លួនព្រះអង្គនៅក្នុងវាំងរហូតដល់ ៧៩ហ្នឹងដែរ ។

វេត : អីចឹងហ្ន៎?

វណ្ណៈ : បាទ!ហើយបានចិន...គាត់ទៅណាស គាត់ទៅមុនបែកបីបួនប្រាំថ្ងៃចឹងណាស ឧបមាថាវៀតណាមចូលជិតដល់ចឹងគាត់ជិះយន្ដហោះទៅមុន ហើយកាលនោះគា ខៀវ សំផន អ្នកមើលបាយទឹក ។

វេត : ហួសចឹង!តែកាលនោះខ្ញុំធ្លាប់បានទៅលេងវាំងដែរ ។

វណ្ណៈ : តែអត់ដឹងទេ?

វេត : អត់ដឹង ដើរតែមើលណេះណោះនាំគ្នាសរសើរថាស្អាត ស្អាតណាស់ចេះចុះទៅ តែថាឲ្យសួររកសម្ដេចសីហនុអីអត់ទេមិនបានសួរផង ។

វណ្ណៈ : ចុះដូចកាលនោះទ្រព្យសម្បត្តិដែលប្រជាជនរត់ចេញពីក្រុងហ្នឹងនៅច្រើនណាស់មើលទៅ ។

វេត : ក្អួយអ្ហើយ!ខ្ញុំមិនថាអីទេពេញៗទាំងអស់ ពេញហើយចេះតែនាំគ្នាឡើងទៅចុះផ្ទះថ្មមួយៗនោះឡើងទៅឃើញរាប់ហើយបើកវ៉ាន់គេមិនដឹងជាស្ដាយដល់ថ្នាក់ណាទេ មិនដឹងជាទៅដល់ណាហើយទេនាក តែបានតែសរសើរចឹងឯង ។

វណ្ណៈ : កាលនោះគ្មានប្រជាជនរស់នៅទេមានតែកម្មករ មានតែយោធាអីទេមីង?

វេត : ចា៎!មានតែស្ថាប័ន ។

វណ្ណៈ : មានតែស្ថាប័នគេទេក្រៅពីនោះមិនមានអីទេ ។

វេត : ខ្ញុំកាលនោះកុំអីមិនបានចេញពីភ្នំពេញទេ៧៩នោះ តែដោយសារព្រះពាក្យគេថាទេតើកុំអីនៅបានដល់ឥឡូវ ។

វណ្ណៈ : កុំអីបាននៅផ្ទះថ្ម!

វេត : ចា៎!នៅបានយកបាត់ហើយ ព្រោះអីគេថាបើនៅអត់កើតទេយួនជិតមកដល់ហើយ តែយួនមកដល់ហ្នឹងគេអាលាក់សសៃកែងសសៃអីទៅណាស ពាក្យគេឃោសនានោះក្លួយហើយយើងមិនខ្លាចអាកន្ទែងផាប់នោះ ។

វណ្ណៈ : បាទ!តែមីងនៅក៏អត់បានដែរព្រោះពេលយួនមកគេដេញប្រជាជនចេញណាសហើយក្រោយមកបានចូលទៅវិញបានហើយទាល់តែមួយខែពីរខែដែរបានប្រជាជនាចូលមកបាន ។

វេត : ខ្ញុំរត់មកដល់ត្រឹមត្រពាំងក្រឡឹងហ្នឹងហើយបានរត់ចូលទៅហ្នឹង!

វណ្ណៈ : ហ្អស!បានបើចឹងបាន ចូលទៅសារក្រោយហ្នឹងបានប្រហែលមួយខែហ្នឹងយើងទៅវិញបានណាស ។

វេត : បើអត់ហ៊ានហ្នឹងចេះតែថាអត់បានទេ ទោះបីយើងទៅគេចាប់យើងអីចេះអីចុះគេចាប់យើងអាលាក់សសៃកែងចងដឹកទាំងយួរៗអី អីណាដោតស្ទឹកត្រចៀកអីចេះចុះ ហើយយើងប្រជាជនយើងខ្លាចណាស់ ។

វណ្ណៈ : បើកុំតែពូស្ទូរចឹងមិនប្រថុយរត់មកផាប់តាមផ្លូវចឹងទេ?

វេត : ចា៎!មិនមែនប្រថុយរត់អត់បាយអត់ទឹកអីទេក្លួយអ្ហើយ កុំតែពូចឹងតើ ។ ហើយទាំងគេទាំងឯងឆ្មៀតនាំគ្នាប្រជ្រៀតមក ។ ខ្ញុំវារត់ជិះឡានៗឡើង២៥គ្រឿងពួកខ្ញុំនោះ ។

វណ្ណៈ : ហ្អស!អ្នកដែលថ្មើរជើងមកស្លាប់តាមផ្លូវអត់មានអីស៊ីដែរហ្នឹងណាស ។ ចឹងមីងសំណាងហើយឡានជិះមកដល់ណា?

វេត : ជិះទាល់តែផុតផ្លូវគេនោះ តែគ្រាន់តែខ្ញុំតាំងពីកើតពោះម៉ែមកខ្ញុំមិនដែលស្គាល់ព្រៃភ្នំទេ ក្លួយមកហ្នឹងអត់មានស្គាល់ត្រង់នេះត្រង់នោះទេគេទៅត្រង់ណាក៏ចេហតែទៅៗ ។

វណ្ណៈ : តែមីងមកទាំងប្តីទាំងប្រពន្ធ?

វេត : ចាស

វណ្ណៈ : ហើយកូនមួយទៀត?

វេត : កូន កូនខ្ញុំតូចកាលនោះមិនដឹងប៉ុន្មានខែទេ ។

វណ្ណៈ : ហ្អស!នេះកុំតែមានឡានជិះ បើអត់ឡានជិះតាមផ្លូវយ៉ាប់ទៀតកូនហ្នឹង ។

វេត : មានបញ្ហាហើយ ដល់ចឹងទៅវាបានរស់តែរស់តែម៉ែហើយនិងកូនទៅប្តីស្លាប់ទៀតគាត់មានជំងឺ ។

វណ្ណៈ : បាទ!ពេលមីងមកៗតាមផ្លូវណាចេញ៧៩ហ្នឹង?

រេត ៖ វាមិន...ចេះតែសួរគេរាល់ថ្ងៃហ្នឹងថាមានអ្នកណាមកជាមួយខ្ញុំដែរអត់ហើយខ្ញុំមកតាមណាអី ខ្ញុំអត់ចេះចាំនឹងគេនោះតែគ្រាន់តែទៅៗដល់ថៃ ។ ទៅដល់ថៃហ្នឹងខ្ញុំឡើងតាមខ្លងយ៉ៃនោះ ក្មួយ កូនខ្ញុំពាក់មានសប៉ុនៗនេះ អាក្មេងតូចហ្នឹងណាសបីហ្នឹងណាស...

វណ្ណៈ ៖ ចុហបានមាសពីណាពាក់?

រេត ៖ ក្មួយចាំខ្ញុំប្រាប់ក្មួយឯង! យើងសំរាកកន្លែងណាយើងរើសកន្លែងនោះ ខ្សែកណាសអ្នកខ្លះគេដាក់បន្តោងដែកកេះ អ្នកខ្លះគេបោះចោលចឹងទៅណាសហើយកូនខ្ញុំវាចេះតែវាតេះតាស់ចឹងទៅហើយខ្ញុំហូបបាយចឹងទៅវារៀរទៅស្រវ៉ា ។ ហើយកំលោះៗកាលនោះគេហៅនារីគេថាមើលឲ្យធារ៉ាពាក់ទៅមើល ហើយខ្ញុំថា កុំពាក់អីនាំតែធ្ងន់ទេចុះមាសម៉ាតំឡឹងកន្លះនោះចឹងក៏ពាក់ទៅទៅដល់ខ្លងយ៉ៃ អាឈុតខ្មៅវានោះវាយាមមិនដឹងប៉ុន្មាន(ស្តាប់អត់បាន) វាឆែកទាំងម៉ែទាំងកូនទាំងអស់ដល់ហើយវាទៅឆែកចំកូនហ្នឹងឃើញមាសវាថាល្អៗហើយចឹងវាឲ្យដប់បាតវាថាយកទៅទិញបាយស៊ី ។ ដល់ចឹងឯងណោះនឹកថា ចុំ!មាសប៉ុនណាណើគេឲ្យដប់បាតចឹងលុយគេមិនដឹងថ្លៃប៉ុណ្ណាទេ...

វណ្ណៈ ៖ ថៃហ្អី?

រេត ៖ ថៃណាក្មួយ! វាឲ្យដប់បាត កាក់ដប់បាតប្រហែលធំជាងមេដើងបន្តិចហើយយើងហ្នឹងក៏អត់ដឹងដែរ អត់ដឹងថាដប់បាតហ្នឹងប៉ុន្មានទេ ។

វណ្ណៈ ៖ ចឹងមាសហ្នឹងថៃយកតែម្តង?

រេត ៖ វាឆែកយកក្មួយ អត់បានទេវាឆែកយកអស់ម៉ាស្រករខ្ញុំអត់មានសល់ទេ បើយើងមិនឲ្យវាវាទាត់ណាសមិនបានទេអាហ្នឹងសុទ្ធតែពួកអាឈុតខ្មៅ ។

វណ្ណៈ ៖ បើមិនឲ្យវាទាត់យើងហ្អី?

រេត ៖ ចា៎!

វណ្ណៈ ៖ យើងត្រូវតែឲ្យចឹងម៉ង?

រេត ៖ ចា៎! ចុះរដ្ឋអំណាចគេក្មួយដែលយើងចូលប្រទេសគេ ។

វណ្ណៈ ៖ គេយកមាសយើងទទេៗ?

រេត ៖ ចា៎! បើប្រៀបធៀបឥឡូវដប់បាតស្មើនឹងម៉ាពាន់ប្រាំរយវាយកចឹងទៅ ។ ហើយពេលយើងឆ្លងទៅវាមិនមានអ្នកល្អអ្នកអាក្រក់ចឹងក្មួយថៃណាស សំរាប់ប្រជាជនគេល្អៗគេដុះក្បាលពោះស្អុយៗប្តីប្រពន្ធគេដាំបាយដាក់ធុងទឹកកកមកចឹងណាសហើយឃើញចឹងអីគេយកមកឲ្យយើងចឹងបានថាវាមិនហួសគ្នាទេមានអ្នកល្អអ្នកអាក្រក់ ។

វណ្ណៈ ៖ ចឹងមានល្អមានអាក្រក់ចឹង?

រេត :	ចាំ!

វណ្ណៈ :	តែវាល្អបើវាឃើញរបស់យើងក៏វាចង់បានដែរ ។

រេត :	អើ!វាចង់បានហើយវាយករបស់យើងហើយវាសួរថាមានដាប់មាសដាប់អីមកដែរអត់ចឹងណាស ហើយយើងប្រាប់វាថាអត់ចឹងទៅ ។ ដល់អ្នកខ្លះដូចអូនឯង ខ្មែរយើងដែលរត់ទៅកាលជំនាន់ លន់ នល់ អីគេប្រាប់ថាបើអូនឯងមានមានសយកទៅលាក់ទោប្រយ័ត្នពួកខូចៗ វាយកចឹងណាស លាក់ឲ្យជិតៗទៅកុំឲ្យវាឃើញប្រយ័ត្នវាយកថាចឹងណាសតែវាយកហើយ វាគ្មានឲ្យអីយើងទេចឹងបានខ្ញុំថាវាមានអ្នកល្អអ្នកអាក្រក់ដែរ ។

វណ្ណៈ :	ចឹងបានន័យថាមានខ្មែរយើងនៅក្នុងនោះដែរ?

រេត :	មានខ្មែរយើងច្រើនណាស់ក្មួយអើយ!

វណ្ណៈ :	នៅតាមព្រំដែនហ្នឹងហ្អី?

រេត :	នៅខាងក្នុងបាងកកហ្នឹងក៏មានដែរដល់ហើយចឹងទៅទៅអង្គុយជុំគ្នា គាត់សួរខ្ញុំថា អូនឯងមកពីប្រទេសខ្មែរហ្នឹងនៅភូមិអី ចឹងណាសគេសួរ ។ ដល់នេះខ្ញុំប្រាប់ថាខ្ញុំចេញមកពីភ្នំពេញណាអ៊ី ខ្ញុំក៏ចេញមកពីនោះដែរតែខ្ញុំចេញមកជំនាន់ លន់ នល់ គាត់ប្រាប់ចឹងខ្ញុំចេះតែចាំទៅណាស ។ ចឹងគាត់ប្រាប់ថាបើមានអីៗឲ្យលាក់ទៅ ព្រោះខ្មែរគ្នាឯងនោះ អ្នកខ្លះគេអត់ប្រាប់យើងទេថៃនោះ ។

វណ្ណៈ :	គេប្រាប់យកបុណ្យទៅ!

រេត :	ចាស គេប្រាប់យកបុណ្យ គេនឹកឃើញថាជនជាតិគ្នាឯងណាស ហើយគេមកពេញណាពេញណឹង ណោះក្មួយអើយគេមករកបងប្អូនឃើញយើងភៀសខ្លួនទៅនោះ ។

វណ្ណៈ :	បើនិយាយពីរឿងមាសវិញបើខ្មែរក្រហមប្រមូលប្រហែលជារាប់តោនណាសនៅភ្នំពេញ!

រេត :	អូ!មាសមិនធម្មតាទេ!

វណ្ណៈ :	មីងគិតមើលមាសលក់ទាំងទូៗ មាសពេជ្រអីមានអ្នកណាយកទៅណាបានកាលជំនាន់ខ្មែរក្រហម ។

រេត :	ខ្ញុំប្រាប់ក្មួយឯងអាផ្ទះខ្ញុំនៅជិតផ្សារថ្មីណាស ម្ចាស់គេហើយ ដាក់អាងទឹកណាសចុះផ្ទះគេឡើងពីរបីជាន់ដាក់អាងទឹកហ្នឹងវានៅសំយាបផ្ទះចឹង ដល់ហើយនាំគ្នាមុជទឹកអីហើយយកអាដែកមួយទៅវ៉ៃអាងនោះលេង វ៉ៃអារបៀបក្មេងហ្នឹងណាស វ៉ៃទៅជ្រុះមកក្មួយឯង កំប៉ុងឡើងប៉ុណ្ណេះដល់យកថាសមកចាក់ក្មួយអើយឡើងក្រហមឆ្អិសនាំគ្នាអង្គុយមើលហើយថា ងាប់ហើយវ៉ើយ!ស្អាតៗណាស់អាខ្លះពាក់ដៃអាខ្លះពាក់ក ពាក់លេងហ្នឹងណាស ។ ដល់ចឹង បងឈុនណា គាត់នៅបូព៌ាណាសប្ដីគាត់ឈ្មោះ ដេង គាត់ថា រេតឯងយកខ្លះទៅ ខ្ញុំថាមិនដឹង

យកទៅណាទេបង មិនដឹងយកទៅណាទេ ហើយគាត់ថាយកទៅឲ្យកកូន ឲ្យធីរ៉ាពាក់ទៅ! មិនដឹងពាក់ធ្វើអីទេបង បងឯងយកទៅទុកទៅ ហើយគាត់មិនដឹងយកទៅទុកនៅឯណាទេ ដាក់នៅនឹងថាសហ្នឹងឯងចាកមកឡើងក្រហម តាំងពីផ្កាច័ន្ទតាំងពីដញ្ចៀន និយាយរួមទៅអារបស់ចាស់ៗពីមុនណាស ។ បានថាគាត់ភ្លេចយកទៅហើយចឹងណាសនឹកឃើញវែងឆ្ងាយចឹងណាស ។

វណ្ណៈ : ព្រោះអីចេះពេលចូលមកដំបូងអង្គការប្រាប់ថាឲ្យចេញទៅតែខ្លួនទេអត់ឲ្យយកអីទៅទេ ព្រោះទៅតែបីថ្ងៃមកវិញហើយអីចឹងភាគច្រើនអត់យកទៅទេ ។

រេត : កាលខ្ញុំចេញពេល៧៩ខាងលើថាអីចឹងដែរតើថាចេញពីភ្នំពេញតែបីថ្ងៃទេដូចក្មួយឯងថាចឹងណាសទៅតែបីថ្ងៃទេ...

វណ្ណៈ : ៧៩ប្រើពាក្យហ្នឹងដែរ?

រេត : ចា៎!ថាអីចឹងណាស ចេញតែបីថ្ងៃទេព្រោះអីយន្តហោះទំលាក់ ហើយអាកាលមុនរត់ហ្នឹងយន្តហោះទំលាក់មែន យន្តហោះទំលាក់នៅព្រែកឯងណាសនៅភ្នំពេញគេហៅរោងចក្រក្តាបទ្ទះហ្នឹងយន្តហោះទំលាក់មែនហើយ ។ ដល់ពេលពួកគេថាអីចឹងមកខ្លួនឯងនេះក៏វាជឿដែរ ។ ពេលចេញបីថ្ងៃឃើញអាយន្តហោះលើអាកាសហ្នឹងទៀត អុស!ទូងទាំងៗលើអាកាសហ្នឹងទៀតរឹតតែភ័យឡើងទៀតហើយគ្មាននឹកឃើញអីទេក្មួយ ។

វណ្ណៈ : ចុះកាលជំនាន់នោះមីងដឹងថានៅរោងចក្រក្តាបទ្ទះហ្នឹងគេធ្វើឈើធ្វើ?

រេត : គេធ្វើឈើតើក្មួយ ។

វណ្ណៈ : មីងដែលទៅមើលទេ?

រេត : អត់ ។

វណ្ណៈ : កាលនោះមានឈើយើងអាយើងអីដែរហ្អី?

រេត : ចា៎!

វណ្ណៈ : ហើយកាលជំនាន់នោះព្រៃឈើអីក៏សំបូរ ហើយត្រីសំបូរដែរតែប្រជាជនទូទាំងប្រទេសស្ទើរតែគ្រប់កន្លែងស្លាប់ដោយអត់អាហារហើយហ្នឹងសំលាប់ ប៉ុន្តែក៏មានកន្លែងខ្លះ ភូមិខ្លះមានហូបដែរ វាមានណាស ។ ដូចនៅបាត់ដំបងដូចពីតំបន់៤តំបន់៥អីចឹងហូបចុកខ្វះខាតតែតំបន់បីអត់អីទេចេះដួយលាក់ឲ្យប្រជាជនហូបចុក ចឹងក៏មានដែរ ។ គេថា តាញឹក លី ខ្ញុំទៅជួបគាត់គេហៅតែពុកលីៗ ហើយអ្នកនៅអាមេរិកអីគេរត់មកពីភ្នំពេញមកនៅជាមួយគាត់រស់ហើយគេបានទៅអាមេរិកចឹងគេផ្ញើលុយឲ្យគាត់ចាយដែរ ចឹងមានល្អដែរណាសមិនអាក្រក់ទាំងអស់ទេ ខ្លះក៏មានចិត្តមេត្តាចឹងដែរ ។

រេត ៖ ចា៎!មានអ្នកល្អដែរ ។

វណ្ណៈ ៖ ចុះដូចថាពេលមីងរត់ទៅដល់ជំរុំហើយចឹងឆ្នាំ៧៩ហ្នឹងដែរហ្អី?

រេត ៖ ឆ្នាំ៧៩មកដល់ថៃហើយ ។

វណ្ណៈ ៖ កាលនោះម៉េចបានមីងអត់រត់ទៅបរទេស ទៅអាមេរិក កាណាដាអីចឹង?

រេត ៖ ខ្ញុំគេឲ្យទៅដែរតើក្មួយតែខ្ញុំនឹកឃើញថា...កាលនោះគេរៀបចំឲ្យទៅណាស តែខ្ញុំគេរៀបឲ្យមានគ្រួសារ បើគ្រួសារខ្ញុំមុនស្លាប់ ។ ស្លាប់បានប៉ុន្មានខែក៏ខ្ញុំមានគ្រួសារទៀត ដល់មានគ្រួសារទៀតទៅបែកគ្នា...

វណ្ណៈ ៖ ចឹងមីងកាលទៅដល់ស្រុកថៃគេរើសឲ្យទៅស្រុកក្រៅអីដែរ?

រេត ៖ ចាស គេរើសច្រើនណាស់ក្មួយអ៊ីយចឹងបានខ្ញុំស្តាយក្រោយ ។ គេរើសមិនបាច់ទម៉ាយប៉ៗម៉ាង៉ែមិនបាច់ទេ តែដោយខ្សែកខ្ញុំចឹងគ្រួសារខ្ញុំគាត់ធ្វើទាហាន ដល់ធ្វើទាហានៗខ្មែរក្រហមយើងហ្នឹងណាស គាត់មកមុខដល់ចឹងទៅគេហៅឲ្យខ្ញុំទៅ ខ្ញុំថាអត់ទៅទេបែកគ្រួសារខ្ញុំ ព្រោះអីគ្រួសារខ្ញុំគាត់ទៅមុខបាត់ហើយខ្លាចយើងទៅគេថាប្តីនៅនេះប្រពន្ធទៅនោះជិតប្តីជិតអីចឹងទៅណាស យើងមានជំហរហ្នឹងក៏អត់ទៅទេ ហើយអ្នកខ្លះហថាទៅគិតអីច្រើនទេ ចាំស្រុកឯករាជ្យចាំជួបគ្នាចឹងទៅបានគេទៅៗអីចេះ ។ ហើយអ្នកដែលទៅហ្នឹងសុទ្ធតែនៅជុំៗគ្នាហ្នឹងឯងហើយខ្ញុំទើបតែកូនមួយដែរទើបតែទៅពីភ្នំពេញហ្នឹង ។ មានកូនមួយហ្នឹងទេ តែខ្ញុំអត់ទៅ ។ អ្នកស្រុកខ្ញុំគេទៅកាណាដា ហើយអាមេរិក បារាំង...

វណ្ណៈ ៖ បើមីងទៅបែកពីពូហ្អ?

រេត ៖ ចាស បែក ។

វណ្ណៈ ៖ ចឹងក៏សំរេចចិត្តថាមិនទៅទៅ?

រេត ៖ មិនទៅៗ នៅហ្នឹង ។

វណ្ណៈ ៖ កាលនោះមីងនៅខាងសំឡូត ឬខាងម៉ាឡៃ ឬខាងថ្មដាយើងនេះ ។

រេត ៖ នៅខាងអន្លង់វែង!

វណ្ណៈ ៖ នៅខាងអន្លង់វែងទេ?

រេត ៖ ចាស

វណ្ណៈ ៖ នៅជាមួយ តាម៉ុក នៅខាងតាម៉ុក?

រេត ៖ ខ្ញុំនៅបានតែបន្តិចខ្ញុំមកវិញមក ។

វណ្ណៈ ៖ ៧៩ នៅដីថៃអន្លង់វែងហ្អ?

រេត ៖ ចាស!

វណ្ណៈ : ឆ្នាំណាមីងមក?

វេត : ឆ្នាំម៉ាពាន់ប៉ុន្មានហើយទេ ដូច៨២...

វណ្ណៈ : ៨២ នៅអន្លង់វែងមីងនៅបានប៉ុន្មានឆ្នាំ?

វេត : នៅប្រហែលម៉ាឆ្នាំអីហ្នឹងរត់ចេញពីនោះមកទៀតហើយ ។

វណ្ណៈ : ចេញមកខាងណាវិញ?

វេត : ចេញមកនេះនៅខាងនេះ ។

វណ្ណៈ : នៅថ្មដាហ្នឹងហ្អី?

វេត : ចាស នៅថ្មដាហ្នឹងអត់ស្គាល់ដែរហ្នឹងនៅឯជាប់ថៃ ជិតថៃអត់នៅខ្មែរទេ នៅតែព្រំដែនថៃទេ ដីថៃហ្នឹងគេហៅស៊ីសាកេត ហៅសូរិនអីចឹង ។

វណ្ណៈ : ប៉ុន្តែគ្រួសារមកភូមិ?

វេត : ចាសមកភូមិចឹងទៅ ប្រពន្ធៗនៅថៃ ។

វណ្ណៈ : ពេលដែលគ្រួសារឡើងមកវើអីចឹងមីងចេះតែជ័យខ្លាចហើយបារម្ភ?

វេត : ចាស ចេះតែភ័យខ្លាចហើយដល់ពេលគ្រួសារត្រលប់ទៅវិញចឹងទៅចេះតែទៅសួរគាត់ទៅណាសថាបងឯងទៅវើហ្នឹងសុទ្ធតែយួនឬក៏មានខ្មែរដែរសួរអីចឹងណាស ។ ហើយគាត់ថាភាគច្រើនប្រយុទ្ធជាមួយយួនទេបើទាហានខ្មែរមកដល់សារភាពហើយ ថាមកពីស្រុកណាអាអូនអីចឹងទៅណាសក្រែងលបងប្អូនបងអី ដល់សារភាពចឹងទៅគេឲ្យនៅក្រោយ ។

វណ្ណៈ : ចុះមីងមានគ្រួសារអីចឹងគេអត់មានឲ្យមកកងដឹកជញ្ជូនអីទេ?

វេត : អត់ អត់ដែលទេ ។

វណ្ណៈ : ចុះមីងស្គាល់ប្រធានកងពលដែរអត់កាលវើជាមួយយួន ប្រធានកងពលខ្មែរក្រហម?

វេត : គាត់ស្លាប់បាត់ហើយ ។

វណ្ណៈ : ពីណាគេ?

វេត : តាស៊ុម តែគាត់ស្លាប់បាត់ហើយ ។

វណ្ណៈ : គាត់ស្លាប់ដោយសារអី?

វេត : ឈឺ កើតទាចទឹក ។

វណ្ណៈ : អស ហើយមានពីណាទៀត?

វេត : គាត់នេះអស់ហើយ បែកបាក់កគ្នា ។

វណ្ណៈ : ចុះ តារ៉ែមអីនោះ?

វេត : តារ៉ែម ហ្នឹងក៏ស្លាប់ ស្លាប់អស់ហើយ ។

វណ្ណៈ ៈ អស!តាបូរ៉ា?

វេត ៈ ចាស នៅតែក្មេងក្រោយៗ ។

វណ្ណៈ ៈ ក្រោយៗទៀតមាន គីម ពៅ អីចឹងទៅ?

វេត ៈ ចាស នៅ តាពៅ តែឥឡូវគាត់នៅក្នុងអីចឹងទៅ ដល់ចឹងទៅអត់មានអ្នកណាផង ។

វណ្ណៈ ៈ ចុះមីងនៅថ្នដារហូតដល់សមាហរណ៍កម្ម ឬក៏ទៅណាទៀតទៅសំឡូតទៅម៉ាឡៃ?

វេត ៈ ខ្ញុំពេលសមាហារណ៍កម្មហ្នឹងខ្ញុំនៅអីជីរុំម៉ាក់មួក ។

វណ្ណៈ ៈ មីងអត់ទាន់ចូលទេនៅក្នុងជីរុំ?

វេត ៈ ចាស នៅក្នុងជីរុំហ្នឹង ដល់សមាហារណ៍កម្មហើយបានរដ្ឋាភិបាលឲ្យពួកខ្ញុំមកនៅចំការជ្រៃ ទល់ឥឡូវហ្នឹងទៅ ។

វណ្ណៈ ៈ ចុះមីងរៀបការគ្រួសារក្រោយឆ្នាំណា?

វេត ៈ ៨២!

វណ្ណៈ ៈ ចឹងបន្ទាប់ពីប្ដីមីងស្លាប់ប៉ុន្មានបានរៀបការ?

វេត ៈ ប្រហែលជាប្រាំខែមិនដឹងក្មួយប្រហែលប៉ុណ្ណឹងហើយ ។

វណ្ណៈ ៈ កាលនោះប្ដីមីងមានតួនាទីអីគេដែរកាលឆ្នាំ៨២?

វេត ៈ ដែលការហ្នឹ?

វណ្ណៈ ៈ បាទ ក្រោយធ្វើធំគ្រាន់បើទេ?

វេត ៈ អត់ទេគាត់តូចតាច ។

វណ្ណៈ ៈ ប្រធានវរៈអីដែរទេ?

វេត ៈ បែបអនុសេនាធំ ។

វណ្ណៈ ៈ ពេលហើយចឹងអ៊ុនគាក់ចូលមកអត់ទាន់បោះឆ្នោតទេចឹងនៅខ្មែរក្រហមនៅឡើយ?

វេត ៈ ចាស នៅនៅខ្មែរក្រហមនៅឡើយ ហើយព្ទសូវតែអ៊ុនគាក់ៗឃើញអាកាទុំរុយគេសន្តោង ថ្ងៃឡើងចឹងអន្ទុយមើលហើយ ។ កាលនោះបន់ឲ្យតែឯករាជ្យនឹងអាលមកស្រុកនឹកស្រុកពេក មួយៗថាអ៊ុនគាក់ចូលហើយឲ្យសន្តិភាពទៅ អត់អាលឹង ព្ទសូវតែគេហៅអឹ ខៀវ សំផនទៅ ចចារគ្នានៅភ្នំពេញថា អុស!អឺៗយើងចូលភ្នំពេញហើយជិតបានទៅផ្ទះហើយយើង ។ ាក វិញអត់ទៀតហើយពិបាកណាស់ ។

វណ្ណៈ ៈ កាលនោះតា សុន សេន តាខៀវ សំផន អីមកដល់ហ្នឹងទេ?

វេត ៈ ចា៎!គាត់នៅកន្លែងគាត់ ។

វណ្ណៈ ៈ កន្លែងគាត់នៅឯណា?

រេត ៖ កន្លែងគាត់នៅថៃ យើងនៅនេះអត់ដែលឃើញគាត់ទេ ។

វណ្ណៈ ៖ ចុះពេលសមាហារណ៍កម្មហើយមីងសប្បាយចិត្តទេ?

រេត ៖ អូស សប្បាយណាស់ក្មួយអើយបានទៅស្រុក បានទៅធ្វើបុណ្យធ្វើទានអីហ្នឹងណាស ។ ណឹកគុណរាជរដ្ឋាភិបាលយើងដែរ

វណ្ណៈ ៖ បានទៅស្រុកហ្អី?

រេត ៖ ចា៎!

វណ្ណៈ ៖ ចុះពូពេលធ្វើសមាហារណ៍ហើយគាត់ឈប់ធ្វើទាហានហើយធ្វើស៊ីវិលម្ដងហ្អី?

រេត ៖ ចា៎!គាត់ខាងប្រធានបរិស្ថាន ខាងប្រធានអភិរក្សណាស ដល់ឥឡូវអាយុគាត់ដល់អាយុអាត្រែតចឹងក៏រដ្ឋាភិបាលឲ្យចូលខាងក្រុមប្រឹក្សាវិញអត់ឲ្យឈប់ទេ ។

វណ្ណៈ ៖ អត់ឲ្យឈប់ទេ គាត់ចេះដឹងដែរ?

រេត ៖ គាត់ថ្នាក់ទី៦ពីសង្គម ។

វណ្ណៈ ៖ អស!ចេះច្រើនណាស់ ។

រេត ៖ បារាំងក៏ចេះ អង់គ្លេសក៏គាត់ចេះ ថៃក៏ចេះ ។

វណ្ណៈ ៖ ហ្នឹងហើយទុកអ្នកចេះដឹងឲ្យធ្វើការបន្តទៀតចឹងល្អហើយ ព្រោះគាត់ចាស់អាយុច្រើនមែនតែកំលាំងនៅមានធ្វើបានហើយ ។

រេត ៖ ឥឡូវសុខភាពគាត់ទន់ខ្សោយដែរ ព្រោះគាត់ឈឺសន្លាក់ ។

វណ្ណៈ ៖ ម៉េចបានឈឺ?

រេត ៖ ឈឺសន្លាក់ តែចាស់ឈឺហើយអាហ្នឹង អត់សូវជាទេឥឡូវឡើងស្រកសាច់ ។

វណ្ណៈ ៖ ចុះមីងប្រៀបធៀបមើលសម័យតស៊ូហើយសម័យឥឡូវមួយណាសប្បាយជាង?

រេត ៖ វា សម័យតស៊ូវាមធ្យមម៉េចបានថាមធ្យមមិនសូវសប្បាយទេ សប្បាយតែប្រពន្ធៗវានៅដីថៃណាសតែសំខាន់យើងគិតគូមកគ្រួសារយើងប្ដីសឹមកស្រុកមកភូមិចឹងអាហ្នឹងម្យ៉ាងកាលពីនៅខាងក្នុងមានទាហានខ្មែរមកប្រយុទ្ធចឹងមិនដឹងបងគេបងឯងក៏មិនដឹង ចេះតែព្រួយបារម្ភអីចឹងបានម្នាក់ៗថាអូយ!ឲ្យបានសន្តិភាពទៅលោកតាលោកយាយអើយឲ្យឆាប់ឃើញបងឃើញប្អូន ។ ដល់មកសម័យនេះវាសប្បាយហួសប្រមាណហើយព្រោះមានផ្លូវ មានមន្ទីរពេទ្យ មានសាលារៀនហើយទីមួយទៀតយើងចង់ដើរទៅណេះទៅណោះអីបានតាមចិត្តឲ្យតែមានលុយ ។

វណ្ណៈ ៖ ហើយនៅទីនេះភូមិឃុំដូចទើបតែបង្កើតថ្មីៗដែរ?

រេត ៖ អត់ទេរៀបចំតាំងពីសមាហារណ៍កម្ម ។

វណ្ណៈ ៖ បាទ!គាំងពីសមាហារណ៍កម្មមកហើយហ្ន?

រេត ៖ ចាស គាំងពីសមាហារណ៍កម្ម ។

វណ្ណៈ ៖ ឥឡូវមានមនុស្សមករស់នៅច្រើន?

រេត ៖ ច្រើនណាស់ក្មួយ ច្រើនទៅៗហើយនៅគ្រប់កន្លែងនៅខាងណោះៗ ។

វណ្ណៈ ៖ កាលមុនមានតែកន្លែងសត្វយំច្រើនហ្អី?

រេត ៖ ចាស!

វណ្ណៈ ៖ ឥឡូវសត្វអស់ហើយ?

រេត ៖ អត់ វាទៅឆ្ងាយ ។

វណ្ណៈ ៖ ទៅឡើងភ្នំអស់ហើយហ្អី?

រេត ៖ ចាស!ហើយឥឡូវប្រជាជនសប្បាយដូចថាទៅធ្វើចំការបានលុយបានកាក់វាស្រួលណាស ។

វណ្ណៈ ៖ មីងបានធ្លាប់ទៅលេងស្រុកកំណើតប៉ុន្មានដងហើយ?

រេត ៖ អស!រាប់មិនឈ្នះទេខ្ញុំឲ្យតែនឹកឃើញចង់ ជួនកាលបងគេហៅពីនោះមកឲ្យកូនជូនឡានទៅពីប

វណ្ណៈ ៖ អស!មានឡានស្រួល ។ អីចឹងចូលឆ្នាំអីទៅមិនសូវខានទេចឹង?

រេត ៖ ចាស អត់សូវខានទេ ។ ជួនកាលទៅខ្ញុំដើរចោលកូនញឹកអានិតកូនដែលវាធំក្រោយៗថា កូនឯងទៅលេងទៅទុកអញនៅចាំផ្ទះម្តងព្រោះអញដើរឡើងឆ្អែតហើយ ចឹងក៏ទៅៗ ។

វណ្ណៈ ៖ ទៅលេងបងប្អូនសាច់ញាតិ?

រេត ៖ ទៅលេងបងប្អូន ទៅលេងណោះណោះចឹងទៅណាសក្មួយ ។

វណ្ណៈ ៖ ចឹងខ្ញុំចង់សួរមីងតិចទៀត ដូចសព្វថ្ងៃមានតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមអីចឹង ដោយសារតែប្រទេសយើងចូលជាមួយអង្គការសហប្រជាជាតិគាំងពីឆ្នាំហាជាង ហើយទៅ នៅក្នុងសង្គមហ្នឹងទោះបីគាត់ថាមិនបានសំលាប់មិនបានបញ្ជាឲ្យសំលាប់មនុស្សអីចឹងមែនដូច ខ្សៀវ សំផនអីគាត់និយាយណាស ប៉ុន្តែយើងមើលជារួមទៅនៅក្នុងសម័យដឹកនាំរបស់គាត់ ស្លាប់មនុស្សអស់ជាងមួយលាននាក់ឯណោះ ស្លាប់មនុស្សច្រើនហើយត្រូវបានបំបែកបំបាក់ គ្រួសារចេញពីផ្ទះសំបែងចេញពីភ្នំពេញអីចឹង ចឹងហើយបទល្មើសទាំងអស់នោះនៅក្នុងផ្លូវ ច្បាប់អន្តរជាតិគេបានដាក់ទោសអ្នកទាំងអស់នោះអ្នកដែលបានប្រព្រឹត្តខុសអីចឹង ដល់អីចឹង ហើយបានយើងមានតុលាការអន្តរជាតិនិងតុលាការជាតិយើងរួមគ្នាធ្វើការកាត់ទោសអ្នកដែល បានធ្វើឲ្យមនុសស្លាប់ចឹងណាស ។ ចំពោះមីង មីងគិតយ៉ាងម៉េចដែរចំពោះតុលាការកាត់ ទោសមេដឹកនាំធំៗថាជាការត្រឹមត្រូវឬមិនត្រឹមត្រូវ?

រេត ៖ ចា៎! ខ្ញុំគិតថាវាត្រឹមត្រូវដែរក្មួយ បើតាមយល់ណាស មានតុលាការកាត់ទោសកាត់អីចឹងវាត្រឹមត្រូវហើយខ្ញុំឯកភាព ។

វណ្ណៈ ៖ ចឹងមីងគិតថាតុលាការមានប្រយោជន៍អីខ្លះដែរ?

រេត ៖ ទេ មានប្រយោជន៍ដល់ប្រជាជនដែរដែលគ្នាមានបងប្អូនអីស្លាប់នោះណាស អាចស្រាវជ្រាវរកអីខ្លះៗចឹងដែរ ។

វណ្ណៈ ៖ បាទ! ចឹងខ្ញុំអគុណមីងច្រើនហើយដែលបានផ្ដល់បទសំភាសន៍ ។

ចប់